– មិនត្រូវជួសជុលឬកែសម្រួលនៅពេលដែលចលករកំពុងធ្វើការ

– ពេលបត់ឆ្វេងឬស្តាំក្នុងករណីមានរ៉ឺម៉ក ត្រូវជាន់ឈ្នាន់ហ្វ្រាំងរ៉ឺម៉កឲ្យស្របនឹងហ្វ្រាំងចង្កូត

– ពេលធ្វើការជាមួយអង្គប់វាយដី ត្រូវតែភ្ជាប់របាំងការពារ

**ប្រយ័ត្ន: ហាមបើកគម្របធុងទឹកនៅពេលចលករក្តៅខ្លាំង។**

## ២. ពេលដឹកជញ្ជូន:

– ត្រូវដាក់កន្លាស់ខ្ទាស់អ័ក្សរបស់រ៉ឺម៉កឲ្យបានត្រឹមត្រូវ



– ហាមមនុស្សជិះលើគែមរ៉ឺម៉កដោយសំយ៉ុងជើងនិងហាមក្មេងជិះជិតអ្នកបើកបរ

– ផ្នែកខាងក្រោយនៃរ៉ឺម៉កត្រូវមានភ្លើងសញ្ញាឬបន្ទះដែលមានចំណាំងផ្លាត

– ហាមមិនឲ្យក្មេងមិនទាន់គ្រប់អាយុបើកបរគោយន្ត

– ហាមមិនឲ្យក្មេងជិះលើគោយន្ត

– ហាមដឹកសំពីងសំពោងលើសកំណត់



– ពេលបើកបរត្រូវលើកចន្ទល់

– ពេលបត់ឆ្វេងឬស្តាំត្រូវមានការប្រុងប្រយ័ត្នជាប់ជានិច្ច។



# ព្រឹត្តិប័ត្របច្ចេកទេស
# នាយកដ្ឋានវិស្វកម្មកសិកម្ម
# នៃអគ្គនាយកដ្ឋានកសិកម្ម



# សុវត្ថិភាពក្នុងការប្រើប្រាស់គោយន្ត

រៀបចំដោយ:
ការិយាល័យបណ្តុះបណ្តាលនិងអភិវឌ្ឍន៍សហគមន៍
ទូរស័ព្ទ: ០២៣ ៨៨៣ ០៩០

ឆ្នាំ២០១៤

## ១.សុវត្ថិភាពក្នុងការប្រើប្រាស់គោយន្ត

ដើម្បីការពារទុកជាមុននូវគ្រោះថ្នាក់ទាំងឡាយដែលអាចកើតឡើងជាយថាហេតុ  អ្នកប្រើប្រាស់គ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្មត្រូវមានការប្រុងប្រយ័ត្នគ្រប់ពេលវេលាក្នុងពេលអនុវត្តការងារ។

### ១.១ មុនពេលបញ្ឆេះគោយន្ត

– ត្រូវត្រួតពិនិត្យកិច្ចថែទាំបច្ចេកទេសប្រចាំថ្ងៃ

– ត្រូវត្រួតពិនិត្យស្ថានភាពចង្កឹះលេខឲ្យស្ថិតនៅក្នុងទីតាំង ឯករាជ្យ (ណឺត)

– ត្រូវត្រួតពិនិត្យអំប្រាយ៉ា(ស្ថានភាពផ្តាច់)

– ត្រួតពិនិត្យសម្ពាធកង់ (១.៨-២.០ $kgf/cm^2$)

– ដាក់ចន្ទល់គោយន្ត

– ត្រូវត្រួតពិនិត្យប្រព័ន្ធចង្កូត



ចន្ទល់

### ១.២ ពេលបញ្ឆេះគោយន្ត

– ត្រូវដាក់ដៃបញ្ចាប្រេង (ហ្គារ) ក្នុងស្ថានភាពមធ្យម



– ពេលបញ្ឆេះចលករមិនត្រូវដាក់ដៃរវៃឲ្យនៅចំណុចខាងលើទេ ពីព្រោះនាំឲ្យមានគ្រោះថ្នាក់



– ពេលបញ្ឆេះគោយន្តត្រូវដាក់ដៃរវៃឲ្យនៅត្រង់ចំណុចក្រោម



– ហាមបង់កក្រម៉ានៅពេលបញ្ឆេះចលករ

– ត្រូវពាក់មួកការពារ(បើអាចធ្វើបាន)

### ១-៣ ពេលចលករធ្វើការ

– ស្តាប់សូរប្លែកក្នុងចលករ

– ពិនិត្យការលេចជ្រាបគ្រប់កន្លែង

– ត្រូវលើកចន្ទល់

– បញ្ចាចង្កឹះលេខអំប្រាយ៉ាដោយសន្សឹមៗ

– ពេលបើកថយក្រោយត្រូវប្រើលេខល្បឿនយឺតនិងបញ្ចាចង្កឹះអំប្រាយ៉ាសន្សឹមៗ

– ពេលបើកបរចុះផ្លូវចំណោតត្រូវប្រើលេខល្បឿនយឺត ចៀសវាងការចាប់ហ្វ្រាំងចង្កូតបង្ខំ